# ធម្មនុញ្ញសហគមន៍សាលារៀន

**Collaborative. Respectful. Communication.**

**សហការ។ គោរព។ ការទំនាក់ទំនង។**

ធម្មនុញ្ញសហគមន៍សាលារៀនដូចតទៅនេះ គូសបញ្ជាក់ពីការទទួលខុសត្រូវរបស់មាតាបិតា អ្នកថែទាំ អ្នកអប់រំ និងបុគ្គលិកសាលានៅក្នុងសាលារៀនរដ្ឋ NSW ដើម្បីធានាថាបរិស្ថានសិក្សារបស់យើងមានភាពសហការគ្នា ភាពគាំទ្រ និងសាមគ្គីភាព។

## អ្វីដែលសាលារៀនរបស់យើងផ្តល់ឱ្យ

សាលារៀនរដ្ឋ NSW ធ្វើការដើម្បីបង្កើតបរិស្ថានវិជ្ជមានសម្រាប់សិស្ស បុគ្គលិក និងសហគមន៍សាលារៀនទាំងមូល ដែលគាំទ្រការរៀនសូត្ររបស់សិស្ស។ យើងខិតខំដើម្បីធានាថាសិស្សគ្រប់រូបត្រូវបានគេស្គាល់ ឱ្យតម្លៃ និងត្រូវបានថែរក្សា។

### ការអប់រំល្អបំផុតកើតឡើងនៅពេលឪពុកម្តាយ និងសាលារៀនធ្វើ ការជាមួយគ្នា។

ធម្មនុញ្ញសហគមន៍សាលារៀនសម្របតាមផែនការយុទ្ធសាស្ត្រអប់រំ របស់ NSW Department of Education ឆ្នាំ 2018 - 2022។



## បរិស្ថានវិជ្ជមាន

វាជាការសំខាន់ដែលសាលារៀនរដ្ឋ NSW របស់យើងគឺជា បរិស្ថានវិជ្ជមាន ហើយថាមាតាបិតា និងអ្នកថែទាំត្រូវបានគេជូនដំណឹងអំពីការរីកចម្រើនរបស់សិស្ស និងសេចក្តីប្រកាសរបស់សាលារៀន។

មាតាបិតា និងអ្នកថែទាំអាចរំពឹងទុកថា៖

- ត្រូវបានស្វាគមន៍ក្នុងសាលារៀនរបស់យើង ដើម្បីធ្វើការជាដៃគូ ដើម្បីលើកកម្ពស់ការរៀនសូត្ររបស់សិស្ស។
- ការប្រាស្រ័យទាក់ទងពីបុគ្គលិកសាលារៀននឹងត្រូវបានធ្វើឡើង ទាន់ពេលវេលា គួរសម និងផ្តល់ជាព័ត៌មាន។
- ទំនាក់ទំនងដែលមានវិជ្ជាជីវៈជាមួយបុគ្គលិកសាលាផ្អែកលើ តម្លាភាព ភាពស្មោះត្រង់ និងការគោរពគ្នាទៅវិញទៅមក។
- ត្រូវបានប្រព្រឹត្តដោយយុត្តិធម៌។ ការអត់ឱន និងការយល់ដឹងត្រូវ បានលើកកម្ពស់នៅពេលយើងគោរពភាពចម្រុះ។

យើងចាត់ទុកមនុស្សគ្រប់រូបដោយមានការគោរព

យើងផ្តល់អាទិភាពដល់សុខុមាលភាពរបស់សិស្ស និងបុគ្គលិកទាំងអស់

**ឥរិយាបថមិនមានសុវត្ថិភាព** មិនអាចទទួលយកបានឡើយនៅក្នុងសាលារៀនរបស់យើង

យើងធ្វើការរួមគ្នាជាមួយសាលារៀន

**ធានាឱ្យបាននូវបរិយាកាសរៀនសូត្រប្រកបដោយការគោរព ចំពោះសមាជិកទាំងអស់នៃសហគមន៍សាលារៀនរដ្ឋ NSW។**



យើង
បង្កើតបរិស្ថាន
រៀនសូត្ររួមគ្នា

យើង
ទាំងអស់គ្នា
ដើរតួជា
ផ្នែកមួយ

យើងធ្វើការជាដៃគូ
ដើម្បីលើកកម្ពស់
ការរៀនសូត្រ
របស់សិស្ស

## ការប្រាស្រ័យទាក់ទងជាមួយសាលារៀនរបស់យើង

បុគ្គលិករបស់យើងនឹងរកពេលវេលា ដើម្បីនិយាយជាមួយលោកអ្នក នៅពេលពួកគេអាចផ្តល់ជូនលោកអ្នកនូវការយកចិត្តទុកដាក់ពេញលេញ។ សូមចងចាំថា ខណៈពេលដែលបុគ្គលិករបស់យើងស្ថិតនៅក្នុងថ្នាក់ ឬកំពុងទាក់ទងជាមួយបញ្ហាផ្សេងទៀត ពួកគេប្រហែលជាមិនអាចរកចម្លើយជូនលោកអ្នកបានភ្លាមៗទេ។



សាលារៀន និងសហគមន៍របស់យើងនឹងធ្វើឱ្យប្រាកដថា ការប្រា ស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរគឺសមរម្យ ត្រឹមត្រូវ និងងាយ ស្រួលអាន។ យើងសូមលើកទឹកចិត្តឱ្យលោកអ្នកប្រើអ៊ីម៉េល និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសាលា រៀនរបស់លោកអ្នក និងរក្សាឱ្យទាន់បច្ចុប្បន្នភាពនូវព្រឹត្តការណ៍ថ្មីៗ ដែលកើតឡើងនៅក្នុងសហគមន៍សាលារៀន។

ការណែនាំរបស់យើងសម្រាប់មាតាបិតា អ្នកថែទាំ និងសិស្ស ផ្តល់នូវព័ត៌មានដែលមានប្រយោជន៍ អំពីដំណើរការធ្វើបណ្តឹងតវ៉ា៖ https://education.nsw.gov.au/about-us/rights-and-accountability/complaints-compliments-and-suggestions/guide-for-parents-carers-and-students



## ការប្រាស្រ័យទាក់ទងប្រកបដោយការគោរពគឺជាសិទ្ធិ

នៅគ្រប់កន្លែងធ្វើការទាំងអស់ មនុស្សមានសិទ្ធិទទួលបាននូវការគោរព។ ឥរិយាបថមិនអាចទទួលយកបាន និងការវាយលុក មិនមានទីកន្លែងនៅក្នុងសហគមន៍សាលារៀនរបស់យើងទេ។

ដើម្បីធានាសុខុមាលភាពរបស់សិស្ស បុគ្គលិក និងសហគមន៍នៅ ក្នុងសាលារៀនរបស់យើង ជំហានទាំងឡាយនឹងត្រូវបានចាត់វិធានការដើម្បីដោះស្រាយឥរិយាបថមិនអាចទទួលយកបាន។ នេះអាច រួមមានការរឹតបន្តឹងទំនាក់ទំនងជាមួយសហគមន៍សាលារៀន ឬក្នុងករណីធ្ងន់ធ្ងរច្រើនទៀត បញ្ជូនទៅកាន់ប៉ូលីសរដ្ឋ NSW។



## ឥរិយាបថមិនអាចទទួលយកបានអាចរួមមាន ក៏ប៉ុន្តែមិនត្រូវបានកំណត់ចំពោះ៖

- សកម្មភាពឈ្លានពាន ឬបំភិតបំភ័យ ដូចជាអំពើហិង្សា កាយវិការគំរាមកំហែង ឬភាពចូលមកជិតរាងកាយ។
- ប្រើភាសាឈ្លានពាន ឬបំភិតបំភ័យ រួមមានការប្រើភាសាអាសគ្រាម ការបញ្ចេញមតិប្រកាន់រើសអើងលើផ្លូវភេទ ពូជសាសន៍ ឬប្រមាថមើលងាយ ឬប្រើសូរសម្លេងគ្រោតគ្រាត។
- ចាត់ទុកសមាជិកនៃសហគមន៍សាលារៀនដោយភាពខុសគ្នា ដោយសារទិដ្ឋភាពទាំងឡាយដូចជាសាសនា ឬពិការភាព
- ការធ្វើទំនាក់ទំនងមិនសមស្រប និងខ្ជះខ្ជាយពេលវេលា។

សហការ។
គោរព។
ការទំនាក់ទំនង។